# I-ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/១២០០/១២

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និងពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ប្រកាសអោយប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី[illegible] នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង

# ឆ្នាំ ២០០១

----

## ជំពូកទី ១
## ចំណូល ចំណាយនៃថវិកាទូទៅរបស់រដ្ឋ

--------------------------

--------------------------

## ជំពូកទី ៣
## ការកែសំរួលតពចំណូល
## ពាក់ព័ន្ធនឹងអាករពិសេសលើទំនិញមួយចំនួន

មាត្រា ៧ :

ក្នុងការអនុវត្តន៏កំណែអត្រាពន្ធគយ ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀង ស្តីពីតារាងអនុគ្រោះពន្ធគយ មានប្រសិទ្ធភាពរួម (CEPT) សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ធ្វើនៅសឹង្ហបូរី នាថ្ងៃទី២៨ ខែ មករា ឆ្នាំ ១៩៩២ ដូចមានចែងត្រង់ចំណុចលេខ១៥ ក្នុងមាត្រា១ នៃច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ពិធីសារ និងអនុស្សារណៈនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ អាស៊ាន ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០០/០៣ ចុះថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ២០០០ ត្រូវកែប្រែអត្រាខ្លះនៃអាករពិសេសលើទំនិញមួយចំនួន ដែលមានចែងក្នុងមាត្រា ៨៥ នៃច្បាប់ ស្តីពីសារពើពន្ធ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ១៩៩៧ ។

អត្រាផ្សេងៗ និងប្រភេទទំនិញ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៧ :

ត្រូវបានកែប្រែមាត្រា២៥ ក្នុងផ្នែកទី៥ នៃជំពូកទី១ របស់ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ១៩៩៧ ដូចតទៅ ៖

មាត្រា ២៥ ថ្មី :

ពន្ធអប្បបរមា ត្រូវបានកំណត់លើអ្នកជាប់ពន្ធតាមរបបពិត ។ ពន្ធអប្បបរមា ជាពន្ធមួយដាច់ដោយឡែក និងផ្សេងពីពន្ធលើប្រាក់ចំណេញ ។ ពន្ធនេះ ត្រូវបង់ដោយអ្នកជាប់ពន្ធលើប្រាក់ចំណេញ លើកលែងតែអ្នកជាប់ពន្ធនោះ បានទទួលលក្ខណៈសម្បត្តិជាសហគ្រាសវិនិយោគក្នុងក្របខ័ណ្ឌ

ច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ជាធរមាន ។ ពន្ធអប្បបរមា ត្រូវបានកំណត់តាមអត្រា១% (មួយភាគរយ) លើផលរបរប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានា ហើយត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ។

ពន្ធអប្បបរមា អាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានបង់ជាក់ស្តែងតាមវិធាន ដែលមានចែងក្នុងមាត្រា ៣៧ មាត្រា ៣៨ និងមាត្រា ៣៩នៃច្បាប់នេះ ។

បទប្បញ្ញត្តិស្តីពីពន្ធអប្បបរមាដូចមានចែងក្នុងមាត្រានេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ២០០១ តទៅ ហើយពុំមានផលប្រតិសកម្មទេ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ១៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៩ .-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

**បានបង្គំទូលថ្វាយ**

**សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

**គាត ឈន់**

★★★